00380825

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / 09 / 2009
ម៉ោង (Time/Heure): 09:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

001/18-07-2007-ECCC/TC
E1/63

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី "ឌុច"

## សាធារណៈ

## សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ
## ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ -ថ្ងៃជំនុំជម្រះទី ៥៨

រៀបចំដោយ: សែ កុលវុឌ្ឍី និង Natacha WEXELS-RISER

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក Matteo Crippa, លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Natacha Wexels-Riser, លោក ឌុច ផារី, កញ្ញា Aline Briot |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Vincent De Wilde D'estmael, លោក សេង ប៊ុនឃាង, លោក ប៉ាក ចន្ទលីណូ |
| ជនជាប់ចោទ៖ លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច |



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

| |
|---|
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ, លោក François Roux(អវត្តមាន), លោកស្រី Marie-Paule Canizares, លោកស្រី Heleyn Unac, លោក ចាន់ រ៉ាវុធ, កញ្ញា Lucile Nattiez |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ កញ្ញា Silke Studzinsky, លោកស្រី Fabienne Trusses-Naprous, កញ្ញា ម៉ុច សុវណ្ណារី, លោក Alain Werner, កញ្ញា ទី ស្រីនណា, លោក យ៉ុង ផានិត |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោកScott Bywater, កញ្ញា ពេជ្រ ចរិយា, លោក Pierre Cozette, កញ្ញា Julie Massé |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ | ចាប់ផ្តើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៦.២៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាក | ចាប់ផ្តើមម៉ោង៖ ១២.១០ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖១៥.០០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៥ ម៉ោង និង ១៥នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការជំទាស់ទៅនឹងពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីការពារក្តី ចំពោះសំណើរបស់អង្គជំនុំជម្រះ | ៩.០៧ | ៩.២៤ |
| នីតិវិធីក្នុងការធ្វើសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី | អង្គជំនុំជម្រះសាលាដំបូង | ៩.២៤ | ៩.២៨ |
| ការស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី Martine Leufeuvre (E2/85) | អង្គជំនុំជម្រះសាលាដំបូង មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ | ៩.៤០ | ១១.២៧ |
| ការកត់សម្គាល់របស់ជនជាប់ចោទទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី Martine Leufeuvre(E2/85) | អង្គជំនុំជម្រះសាលាដំបូង | ១១.២៩ | ១១.៣១ |
| ការស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើម | អង្គជំនុំជម្រះសាលាដំបូង | ១១.៣៣ | [illegible] |

| | | | |
|---|---|---|---|
| បណ្ដឹងរដ្ឋប្បវេណី អ៊ុក នារី(E2/89) | មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី៣ | ១៣.៣៩ | ១៤.០៧ |
| ការកត់សម្គាល់របស់ជនជាប់ចោទទៅលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុក នារី(E2/89) | អង្គជំនុំជម្រះសាលាដំបូង | ១៤.០៧ | ១៤.១០ |
| ការស្ដាប់នូវសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី Robert Hamill(E2/87) និងការតាំងសំណួរ ទៅជនជាប់ចោទដោយដើមបណ្ដឹងរដ្ឋប្បវេណី | អង្គជំនុំជម្រះសាលាដំបូង មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី១ | ១៤.១២ | ១៦.១៥ |
| ការកត់សម្គាល់របស់ជនជាប់ចោទ | អង្គជំនុំជម្រះសាលាដំបូង | ១៦.១៧ | ១៦.២១ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

***ការជំទាស់ទៅនឹងពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដោយមេធាវីការពារក្ដី***

អង្គជំនុំជម្រះបានយោងទៅលើបញ្ជីពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានអាននៅក្នុងពេលសវនាការកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩។ អង្គជំនុំជម្រះបានស្នើឲ្យមេធាវីការពារក្ដីចង្អុលបង្ហាញថាតើពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីណាខ្លះ ដែលមេធាវីការពារក្ដីចង់ជំទាស់ ហើយត្រូវបង្ហាញអំពីមូលហេតុនៃការជំទាស់នោះមួយប្រយោគ ឬពីរប្រយោគ។ មេធាវីការពារក្ដីនឹងទទួលបាននូវឱកាសដើម្បីបញ្ជាក់ដោយផ្ទាល់មាត់លំអិតថែមទៀត ពីមូលហេតុនៃការតវ៉ានៅចុងបញ្ចប់នៃសវនាការស្ដាប់ចម្លើយសាក្សីដែលបានគ្រោងទុករួចហើយ។ ដើមបណ្ដឹងរដ្ឋប្បវេណីនឹងទទួលបាននូវឱកាសដើម្បីឆ្លើយតបទៅនឹងការបដិសេធនោះដោយផ្ទាល់មាត់ ។

មេធាវីការពារក្ដីបានរំលឹកអំពីការកត់សម្គាល់របស់ពួកគេនៅសប្ដាហ៍មុនទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងមកធ្វើសេចក្ដីថ្លែងការណ៍។ មេធាវីការពារក្ដីបានដកការជំទាស់ចំពោះពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីE2/50។

មេធាវីការពារក្ដីក៏បានធ្វើការកត់សម្គាល់ផងដែរថាដើមបណ្ដឹងរដ្ឋប្បវេណី E2/81និង E2/82 បានដកសំណើក្នុងការមកធ្វើសេចក្ដីថ្លែងការណ៍។មេធាវីការពារក្ដីបានធ្វើការជំទាស់ជាថ្មីម្ដងទៀត អំពី...

មន្ទិលសង្ស័យទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះ ក៏ដូចជាដើមបណ្ដឹងរដ្ឋប្បវេណី E2/77 និង E2/34។ ជាមួយនឹងការគោរពចំពោះដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនមកធ្វើសេចក្ដីថ្លែងការណ៍ មេធាវីការពារក្ដីបានចង្អុលបង្ហាញនូវហេតុផលពីរសម្រាប់ការជំទាស់របស់ពួកគេគឺ៖

- មិនមានភស្ដុតាងបញ្ជាក់ពីទំនាក់ទំនងសាច់ញាតិ ជាមួយនឹងជនរងគ្រោះ E2/22, E2/37 និង E2/66
- មិនមានភស្ដុតាងបញ្ជាក់ពីការឃុំខ្លួនរបស់ជនរងគ្រោះដែលបានយោងនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅមន្ទីរស២១៖ E2/30, E2/35, E2/38, E2/41, E2/49, E2/57, E2/62, E2/63, E2/64, E2/65, E2/69, E2/70, E2/71, E2/73, E2/74, E2/75, E2/76, E2/81, E2/82, E2/83, D25/15, D25/20
- ជាការបន្ថែមចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះ មិនមានភស្ដុតាងបញ្ជាក់ពីទំនាក់ទំនងគ្រួសារជាមួយនឹងជនរងគ្រោះ៖ E3/30, E2/35, E2/38, E2/41, E2/57, E2/63, E2/64, E2/65, E2/69, E2/70, E2/71, E2/73, E2/74, E2/75, E2/76, E2/81, E2/82, E2/83, D25/15, D25/20

**សេចក្ដីណែនាំរបស់អង្គជំនុំជម្រះទាក់ទងនឹងការធ្វើសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី**

អង្គជំនុំជម្រះបានចេញនូវសេចក្ដីណែនាំទាក់ទងនឹងការធ្វើសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី (សូមមើលខាងក្រោម)

**ការធ្វើសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី** Martine Leufeuvre

អង្គជំនុំជម្រះបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី Martine Leufeuvre ។

ជនជាប់ចោទបានទទួលស្គាល់ចំពោះប្រវត្តិរូបរបស់លោក អ៊ុក កេត។

**ការធ្វើសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុក នារី**

អង្គជំនុំជម្រះបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុក នារី។

ជនជាប់ចោទបានធ្វើការកត់សម្គាល់ខ្លះៗទៅលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ។

**ការធ្វើសេចក្ដីថ្លែងការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី** Robert Hamill

អង្គជំនុំជម្រះបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី Robert Hamill
ដើមបណ្តឹងរដ្ឋប្បវេណី Robert Hamill បានតាំងសំណួរទៅជនជាប់ចោទ ០៦ សំណួរ។
ជនជាប់ចោទបានធ្វើការកត់សម្គាល់ខ្លះៗទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

| កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧.៣ | | | | |
|---|---|---|---|---|
| លេខយោងរបស់អជសដ | លេខយោងរបស់កសចស | ឈ្មោះ/ការអធិប្បាយ | ចំណាត់ថ្នាក់ឯកសារ (សំងាត់បំផុត,សំងាត់ ឬសាធារណៈ) | កំណត់សម្គាល់ |
| E2/85.13<br>E2/89.20 | គ្មាន | ឧបសម្ព័ន្ធ២០៖ បញ្ជីឈ្មោះអ្នកទោសកំទេចថ្ងៃទី ០៩ ធ្នូ ១៩៧៧ | សាធារណៈ | 00339169-00339169<br>00328268-00328270<br>00281230-00281230<br>បានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ |
| E5/13.1 | គ្មាន | រូបថត អ៊ុក កេត នៅមន្ទីរស២១ | សាធារណៈ | 00285014-00285014<br>00285003-00285003 |
| E3/400/9 | D25/5/9 | ឧបសម្ព័ន្ធ៩៖ បែបបទដើមបណ្តឹងរដ្ឋប្បវេណី ភឹង ហ្គុតស៊ុនថារី៖ ប្រវត្តិរូបអ្នកទោស ភឹង តុននិងបញ្ជីឈ្មោះអ្នកទោសពីក្រសួងការបរទេស | សាធារណៈ | 00188857-00188859<br>00239013-00239016<br>00188860-00188861<br>មាននៅក្នុង E3 រួចហើយ |
| E68.1 | គ្មាន | បញ្ជីឈ្មោះអ្នកទោសដែលបានកែប្រែ E68.1 | សាធារណៈ | 00329596-00330129<br>ជាពិសេស 00330082<br>បានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ |
| E2/85 | គ្មាន | ទម្រង់បែបបទពត៌មានជនរងគ្រោះ LEFEUVRE Martine | សាធារណៈ: កោសលុប | 00281231-00281238<br>00281239-00281242<br>កោសលុបពត៌មានទាក់ទងនឹងបុគ្គល |
| E2/85.1<br>E2/89.3 | គ្មាន | ឧសម្ព័ន្ធ១៖ លិខិតឆ្លងដែនការទូត LEFEUVRE Martine | សម្ងាត់ | 00281222-00281223 |



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.

| | | | | |
|---|---|---|---|---|
| E2/85.4<br>E2/89.4 | គ្មាន | ឧសម្ព័ន្ធ៤៖ សំបុត្រអាពាហ៍ពិពាហ៍ អ៊ុក កេត និងLEFEUVRE Martine | សម្ងាត់ | 00281224-00281224 (មានតែភាសាបារាំង) |
| E2/85.5<br>E2/89.5 | គ្មាន | ឧសម្ព័ន្ធ៥៖សំបុត្រកំណើតរបស់កូនទី១ | សម្ងាត់ | 00281253-00281253 (មានតែភាសាបារាំង) |
| E2/85.6 | គ្មាន | ឧសម្ព័ន្ធ៦៖សំបុត្រកំណើតរបស់ អ៊ុក នារី | សម្ងាត់ | 00281225-00281225 (មានតែភាសាបារាំង) |
| E2/85.8<br>E2/89.13 | គ្មាន | ឧសម្ព័ន្ធ៨៖ Diplome d'Ingénieur | សម្ងាត់ | 00281226-00281226 (មានតែភាសាបារាំង) |
| E2/85/6 | គ្មាន | លិខិតឆ្លងដែនLEFEUVRE Martine | សម្ងាត់ | 00363527-00363527 (មានតែភាសាបារាំង) |
| E2/89.12 | គ្មាន | រូបថតគ្រួសារ រូបថតរបស់ អ៊ុក កេត នៅស២១ | សាធារណៈ | 00281298-00281303 ជាពិសេស 00281298 និង 00281299 |
| E2/87 | គ្មាន | ទម្រង់បែបបទពត៏មានជនរងគ្រោះ Robert Hamill | សាធារណៈ កោសលុប | 00281599-00281601 កោសលុបពត៏មានទាក់ទងនឹងបុគ្គល |
| E2/87.7 | គ្មាន | ឧបសម្ព័ន្ធ៧៖ ចម្លើយសារភាពរបស់ Kerry George Hamill | សាធារណៈ | 00007535-00007547 |
| E2/87.14 | គ្មាន | ឧបសម្ព័ន្ធ១៤៖ សំបុត្រកំណើតរបស់ Robert Miles Hamill | សម្ងាត់ | 00364931-00364931 |
| E2/87.15 | គ្មាន | ឧបសម្ព័ន្ធ១៥៖ សំបុត្រកំណើតរបស់ Kerry George Hamill | សម្ងាត់ | 00364932-00364932 |
| E140.1 | គ្មាន | ឧបសម្ព័ន្ធ១៖ លិខិតបញ្ជាក់លើឯកសាររបស់ស២១ ទៅកញ្ញា ទី ស្រ៊ុនណា Kerry George Hamill | សាធារណៈ | 00362304-00362304 |
| E2/87.16 | គ្មាន | ឧសម្ព័ន្ធ១៦៖ លិខិតចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់ Rachel Kennedy Hamilton | សម្ងាត់ | 00364933-00364933 |



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C

**<u>ឌីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

១-អង្គជំនុំជម្រះសូមរំលឹកដល់ភាគីថា អង្គជំនុំជម្រះនឹងដឹកនាំនៅក្នុងការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់ចម្លើយចំពោះមុខអង្គជំនុំជម្រះ។
នៅក្នុងសេចក្តីណែនាំដែលផ្តល់ដោយក្រឡាបញ្ជីនៃអង្គជំនុំជម្រះនៅថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០០៩ (ឯកសារលេខ E115) អង្គជំនុំជម្រះបានសម្រេចប្រគល់ភារកិច្ចបង្ហាញខ្លួន/សាកសួរដើមបណ្តឹងរដ្ឋប្បវេណីទៅឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកទទួលខុសត្រូវ។

អង្គជំនុំជម្រះសូមរំលឹកថា ការទទួលខុសត្រូវដូច្នេះរួមទាំងកាតព្វកិច្ចរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការតាំងសំណួរឲ្យបានច្បាស់លាស់ដែលពាក់ព័ន្ធនឹងសំណុំរឿងលេខ០០១ ហើយដឹកនាំដើមបណ្តឹងរដ្ឋប្បវេណីដែលពួកគាត់គួរត្រូវផ្តល់នៅសេចក្តីថ្លែងការណ៍បែបណាដែលពាក់ព័ន្ធនឹងសំណុំរឿង លេខ០០១ ដែលមិនចាកឆ្ងាយ ឬត្រូវពិពណ៌នាអំពីផលប៉ះពាល់ដែលកើតមានចំពោះដើមបណ្តឹងរដ្ឋប្បវេណីនោះ។

អង្គជំនុំជម្រះសូមរំលឹកជាពិសេសទាក់ទងនឹងកថាខណ្ឌទី ៩,១០ និង ១១ នៃសេចក្តីណែនាំដែលបញ្ជាក់ថាសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែពាក់ព័ន្ធជាក់លាក់ទៅនឹងការជំនុំជម្រះសំណុំរឿងលេខ០០១។ ហេតុដូច្នេះហើយ ប្រធានអង្គជំនុំជម្រះស្នើឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវណែនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន ឆ្លើយតបនូវសំណួរដូចតទៅនេះ៖

ក). ឈ្មោះ និងលក្ខណៈសម្គាល់ភិនភាគដោយសង្ខេប របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ឯកសារសម្គាល់អាចជា អត្តសញ្ញាណបណ្ណ, បណ្ណបោះឆ្នោត ជាដើម។

ខ). ការពាក់ព័ន្ធ ឬទំនាក់ទំនងជាមួយនឹងបុគ្គលដែលទទួលរងការធ្វើទារុណនៅមន្ទីរស-២១ (រួមទាំងមន្ទីរស-២៤ ផងដែរ)។ តើដើមបណ្តឹងរដ្ឋប្បវេណីមានភស្តុតាងដើម្បីបញ្ជាក់ពីទំនាក់ទំនងនេះដែរឬទេ? ប្រសិនបើមាន សូមបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

គ). តើមានឯកសារពាក់ព័ន្ធនានា ដែលបញ្ជាក់ពីវត្តមានរបស់បុគ្គលនោះ នៅមន្ទីរស-២១

(ដូចជាប្រវត្តិរូប, ចម្លើយសារភាព, បញ្ជីរាយនាមអ្នកទោស, រូបថត ជាដើម) និងលេខសម្គាល់ ERN ដែលពាក់ព័ន្ធ ដែរឬទេ?

១០. អនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី និយាយតែអំពីអង្គហេតុនានា ដែលពាក់ព័ន្ធនឹងសំណុំរឿង លេខ ០០១ តែប៉ុណ្ណោះ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី មានភារកិច្ចទទួលខុសត្រូវក្នុងការធានាចំពោះការពាក់ព័ន្ធនៃសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងសំណុំរឿង។ ដើមបណ្តឹងរដ្ឋប្បវេណីអាចអនុញ្ញាតឲ្យ អានសេចក្តីថ្លែងការណ៍ ដែលបានរៀបចំទុកជាមុន។

១១. ប្រធានអង្គជំនុំជម្រះ នឹងមិនបង្អាក់ដល់ការថ្លែងសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ប៉ុន្តែប្រសិនបើចាំបាច់ ប្រធានអង្គជំនុំជម្រះនឹងប្រើសិទ្ធដើម្បីធានាថា អ្នកដែលចូលរួមទាំងអស់អាចស្តាប់ឮសេចក្តីថ្លែងការណ៍ ជាពិសេសប្រសិនបើសំណួរទាំងនោះគ្មានការពាក់ព័ន្ធ ឬប្រើពេលវេលាលើសកំណត់។

២-បង្គាប់ឲ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកសវនាការវិញនៅថ្ងៃអង្គារ ទី១៨ ខែសីហា ឆ្នាំ២០០៩ ។

| ដីកាសម្រាប់ការលើកវារកាលសវនាការ |
|---|
| ការពន្យាពេលសវនាការ៖ សវនាការនឹងបន្តទៅថ្ងៃអង្គារ ទី១៨ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោង ៩.00 ព្រឹក ។ |

ភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលធុន្ទី Natacha WEXELS-RISER